ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**KINGDOM OF CAMBODIA**
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No. ១៣៣ MOC / M 2004

# ប្រកាស
## ស្តីពីការផ្ទេរអចលនវត្ថុ

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតលេខ ១៦២០ សហវ.ទរ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- បានឃើញកំណត់ហេតុស្តីពីការផ្ទេរទីតាំងដី និង ឃ្លាំងកន្ទុយរ៉ៃ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤

## <u>សំរេច</u>

**ប្រការ ១ :** ផ្ទេរការគ្រប់គ្រងទីតាំងដី និង ឃ្លាំងកន្ទុយរ៉ៃរបស់មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង ជូនសាលាខេត្តស្វាយរៀង សំរាប់សាងសង់សកលវិទ្យាល័យ ។

**ប្រការ ២ :** នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង រៀបចំជំរះបញ្ជីអចលនវត្ថុទៅតាមបែបបទដែលរដ្ឋបានកំណត់។

**ប្រការ ៣** : អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះអោយមាន ប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤

**រដ្ឋមន្ត្រី**

**ចម ប្រសិទ្ធ**

<u>ចំលងជូន</u>

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដូចក្នុងប្រការ ៣ " ដើម្បីអនុវត្ត "
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ



Ministry of Commerce # 20 A & B Preah Norodom Boulevard, Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http://www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile: (855-23) 426396